# នៅមុខខ្លោងទ្វាររោងចក្រ

ឈុតទី 2/6




អង្គការ
ពលកម្ម
អន្តរជាតិ

រោងចក្រ
កាន់តែប្រសើរ
នៅកម្ពុជា


ບ໊ກ


ថ្ងៃបន្ទាប់ នៅក្នុងរោងចក្រ....
យើងឃើញហើយថ្នាក់លើគេធ្វើបាបពួកយើងបែបនេះ តើយើងទ្រាំនៅស្ងៀមទៀតទេ.?
បើអញ្ចឹង.! ពួកយើងគិតធ្វើម៉េចទៅកុសល.? កុសលឯង ជាប្រតិភូកម្មករនៅទីនេះ...
បើយើងនៅតែទ្រាំ ថ្ងៃនេះគេធ្វើដាក់បុប្ផ ថ្ងៃក្រោយពួកគេច្បាស់ជាធ្វើដាក់ពួកយើងរាល់គ្នាមិនខាន
យើងទាំងអស់គ្នា ត្រូវធ្វើកូដកម្ម
កូដកម្ម? តើមានតែមធ្យោបាយមួយហ្នឹងឬ?
សូមស្តាប់ខ្ញុំអ្នកទាំងអស់គ្នា កូដកម្ម មិនមែនជាដំណោះស្រាយទេ បើមិនដើរតាមដំណាក់កាលរបស់វា ចាំណា..ការចរចា ការផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្តាល បើគ្មានដំណាក់កាលទាំងបីនេះទេ បញ្ហានឹងរីកកាន់តែធំឡើង រវាងកម្មករនិងនិយោជក
ឯងមិនបាច់ មកនិយាយធ្វើជាចិត្តល្អទេ ឯងនិងអ្នកគ្រប់គ្រងជាមនុស្សតែមួយហ្នឹង ឯងមិនដែលចាប់អារម្មណ៍ពីកម្មករទេ


បើអញ្ចឹងមែន ធ្វើម៉េចទើបទាំងសងខាងពេញចិត្តទៅ?
ច្បាប់ បានចែងយ៉ាងច្បាស់ មើលជុំវិញខ្លួនអ្នកឯងមានក្រដាសអាយឡូ បិទលើជញ្ជាំង និយាយពីដំណាក់កាល...មើលសៀវភៅដែលពួកគេឱ្យយើង...គ្រប់យ៉ាងនៅក្នុងសៀវភៅ....ពិភាក្សាជាមួយ ប្រតិភូបុគ្គលិក
បើឯងមិនធ្វើកូដកម្មទេ កុំមកជ្រៀតជ្រែក បើពួកគេស្តាប់ឯង ពួកគេនឹងគ្មានសល់អីសោះ
គ្មានសល់អីសោះ? កំពុងនិយាយគ្នាពីរឿងអីហ្នឹង? ម៉ោងធ្វើការណាមិនមែនម៉ោងនិយាយគ្នាទេ ឆាប់បំបែកគ្នាទៅធ្វើការទៅ បើនៅតែនិយាយគ្នាទៀត ពួកឯងត្រូវកាត់ប្រាក់ខែហើយ
ក្រោយមក
ខ្ញុំសួរអ្នកទាំងអស់គ្នា តើព្រមសំងំឱ្យគេកេងប្រវ័ញ្ចពួកយើងដែរទេ ?


ហានធានាទេថា មិនបាត់បង់ ការងារពេលពួកយើងធ្វើកូដកម្ម? ប្រហែលជារោងចក្រត្រូវបិទ.... បើ អញ្ចឹង បានអ្នកណាចិញ្ចឹមគ្រួសារ យើង ..កុសលអ្នក ចិញ្ចឹម?
មិនបាច់ខ្វល់ទេ ចង់អ្នកណាមិនចូលរួមក៏បើទៅ ខ្ញុំអាច ដោះស្រាយរឿងនេះបាន បើអ្នកណាចង់ចូលរួម សូម លើកដៃឡើង ចាំមើលអ្នកណាស្មោះជាមួយកម្មករ គ្នាយើង
កុសលឯងនិយាយត្រូវមួយផ្នែក កម្មករ មានសិទ្ធិធ្វើកូដកម្ម តែជាកូដកម្មស្រប ច្បាប់ តែអ្វីដែលកុសលឯងនិយាយ គឺ ខុសច្បាប់
ចង់ធ្វើអីទឹង ស៊ីណា? នាងគ្មាន សិទ្ធិ និយាយនៅទីនេះទេ
ខ្ញុំមានសិទ្ធិ ស្តាប់រឿងនេះ ដូចអ្នកគ្រប់គ្នាដែរ ព្រោះនេះមិនមែនជា ការប្រជុំឯកជនដែលរៀបចំដោយសហជីពទេ
សូមគ្រប់គ្នាស្តាប់
ខ្ញុំមិនមែនជាប្រតិភូបុគ្គលិកទេ ខ្ញុំក៏ ដូចអ្នកទាំងអស់គ្នាអញ្ចឹង ជាកម្មករ នៅរោងចក្រ ការងារយើងមិនមែនការងារ ល្អបំផុតទេ តែជាការងារបច្ចុប្បន្នរបស់យើង វាជួយចិញ្ចឹមយើងនិងគ្រួសារ វាផ្តល់ឱ្យយើង នូវមោទនភាព និង កិត្តិយស


....តែខ្ញុំ ក៏គិតដូចអ្នកទាំងអស់គ្នាអញ្ចឹង យើងមានសិទ្ធិ ហើយយើងត្រូវដឹងពីសិទ្ធិរបស់យើង ពេលមានបញ្ហា យើងអាចជួយគ្នាទៅវិញទៅមក
ប្អូនស្រី អ្វីដែលប្អូននិយាយ គឺត្រូវសំរាប់ពួកយើងនៅ ទីនេះ
សួរខ្លួនយើងផ្ទាល់ ថាតើយើងបាន ព្យាយាមគ្រប់មធ្យោបាយអស់ហើយឬនៅដើម្បី រកដំណោះស្រាយដោយសន្តិវិធីមួយ ហើយមិន ប៉ះពាល់យើងទាំងអស់គ្នា
កុសល ឥឡូវដល់ពេលធ្វើ កូដកម្មហើយ ហេតុអីចាំយូ ម៉េះ?
ជឿខ្ញុំទៅ ...មិនទាន់ ដល់ពេលទេ តែបន្តិច ទៀត នឹងដល់ពេល ហើយ


អេ កុសល!!! កុសល!!!
World Brand Clothing
ស៊ុណា ថ្ងៃនេះនាងអស្ចារ្យណាស់ នាងធ្វើមិចបានជាកម្មករយល់ថា បើពួកគេមិនដើរតាមច្បាប់ទេ ពួកគេគ្រប់គ្នានឹងខាតបង់ តើអ្វីដែលនាំអោយនាង ឱ្យនិយាយរឿងទាំងនោះ ?
ខ្ញុំអត់ដឹងទេបង គ្រាន់តែថាម្នាក់ៗត្រូវតែនិយាយពីអ្វីដែលបំរុងនឹងកើតឡើង បើពួកគេធ្វើខុសច្បាប់
ខ្ញុំហៅនាងមកនិយាយពេលនេះ ព្រោះយើងនឹងបង្កើតមុខងារថ្មី ក្នុងសហជីពយើង យើងចង់មានអនុប្រធាន ហើយខ្ញុំជឿថា នាងអាចធ្វើបាន
បើខ្ញុំអាចជួយពួកគេបានតាមរយៈនេះ ខ្ញុំនឹងតាំងចិត្តធ្វើការងារនេះ



កុសល ហេតុអី នាំខ្ញុំមកទីនេះ? មើលទៅខ្ញុំមានបញ្ហាហើយ ព្រោះពួកគេនឹងគិតថាខ្ញុំជាគ្នាកុសលដែរ ហើយកុសលមិនទាន់ប្រាប់ខ្ញុំនៅឡើយទេ ពីរឿងកូដកម្មហ្នឹង
...ហេតុអី ពួកយើងត្រូវរងចាំ មុនធ្វើកូដកម្ម? ប្រហែលជាដារ៉ានិងស៊ីណានិយាយត្រូវហើយ ថាអ្វីដែលកុសលចង់ធ្វើ គឺខុសច្បាប់?
ខ្ញុំដឹងថា អ្វីត្រូវធ្វើ... ហេតុអីឯងឆ្ងល់ខ្ញុំម៉េះ?
ខ្ញុំដឹងថា មានអតិថិជនធំនឹងមករោងចក្រយើង...អតិថិជនធំនោះនឹងមកពិនិត្យមើលនូវថ្ងៃសុក្រនេះ ជាឱកាសដើម្បីធ្វើកូដកម្មហើយ អញ្ចឹងខ្ញុំឡើត ពេលនេះ ចរចារកដំណោះស្រាយល្អសំរាប់យើង
បើយើងធ្វើកូដកម្មពេលអតិថិជនធំមកអញ្ចឹង អតិថិជនធំច្បាស់ជាឈប់កម្ម៉ង់ទិញមិនខាន ជាពិសេសបើយើងធ្វើកូដកម្មខុសច្បាប់
ជឿខ្ញុំបន្តិចទៅបានទេប្អូនស្រី កាលណាមានកូដកម្ម វាស្រេចលើខ្ញុំទេជាអ្នកបញ្ឈប់វា អ្នកគ្រប់គ្រងនឹងឃើញថាខ្ញុំមានឥទ្ធិពលលើពួកគេ នឹងខ្លាចយើងនិងគោរពយើង ថ្ងៃសុក្រយើងនឹងធ្វើកូដកម្ម
ថ្ងៃធ្វើកូដកម្មនៅមុខរោងចក្រ


ខ្ញុំដឹងថា អ្នកទាំងអស់គ្នានឹងមកទីនេះ ព្រោះចង់គាំទ្រ សុខបុប្ផា នេះជា
ការត្រឹមត្រូវ ព្រោះកម្មករទាំងអស់ត្រូវក្រោកឈរ ជួយគ្នាទៅវិញទៅមក
ដើម្បីរកដំណោះស្រាយ ដោយយុត្តិធម៌ សំរាប់យើងទាំងអស់គ្នា? ប៉ុន្តែ
តើអ្នកទាំងអស់គ្នាដឹងទេថា ហេតុអ្វីអ្នកទាំងអស់គ្នាមក
ឈរទីនេះប្រុងនឹងធ្វើកូដកម្ម?
រកយុត្តិធម៌ អោយបងស្រី
សុខ បុប្ផា


....តែភាពយុត្តិធម៌ សំរាប់ បុប្ផា នឹងនាំឱ្យ ខុសច្បាប់?
ខុសច្បាប់អី? គ្រប់គ្នាដឹងហើយ ថាកម្មករដូចជាពួកយើងមានសិទ្ធិ ធ្វើកូដកម្ម
ត្រូវហើយ កម្មករមាន សិទ្ធិធ្វើកូដកម្ម តែពួកគេក៏ត្រូវតែមាន ការទទួលខុសត្រូវក្នុងការប្រើសិទ្ធិនោះឱ្យ បានត្រឹមត្រូវ ផងដែរ
តែបើយើងមិនធ្វើសកម្មភាព អ្នកណាការពារពួកយើង ?
បើយើងធ្វើត្រឹមត្រូវ ច្បាប់ជាអ្នកការពារយើង ឯណាអ្នកដែលជំរុញអោយអ្នកទាំងអស់គ្នាធ្វើ កូដកម្ម? តើគាត់បានពន្យល់ច្បាស់អត់ ពីជំលោះ នេះ? តើគាត់ធ្វើតាមច្បាប់អត់?
ត្រូវហើយ ឯណាកុសល? អត់ឃើញ តែគាត់ម្នាក់គត់!
មានអ្នកណាប្រាប់អ្នកទាំងអស់គ្នាទេថា បុប្ផាសុំច្បាប់ពិសេស ទៅមើលម្តាយឈឺ ព្រោះនាង អស់ថ្ងៃឈប់ប្រចាំឆ្នាំ?


ផ្នែកគ្រប់គ្រងផលិតបានជួយនាង ដោយប្រាប់នាងឱ្យធ្វើការបន្ថែមម៉ោង សង ជំនួសថ្ងៃដែលនាងឈប់
តែអោយតែយើងធ្វើការបន្ថែមម៉ោងគឺបានប្រាក់ថែមម៉ោងហើយ
ត្រូវ...ពេលអ្នកទាំងអស់គ្នាធ្វើការនៅថ្ងៃខុសពីថ្ងៃធ្វើការធម្មតា អ្នកអាចបានប្រាក់ថែមម៉ោង គេអោយបុណ្យឈប់ក្នុងពេលបុណ្យអស់ ថ្ងៃឈប់ជាប្រចាំនោះអស់ទៅហើយ
...អញ្ចឹង បញ្ហាកើតឡើងដោយសារគេប្រាប់បុណ្យមិនច្បាស់ថាតើថ្ងៃធ្វើការថែមនោះ គិតដូចថ្ងៃធម្មតាមិនមែនគិតដូចថ្ងៃធ្វើការថែមម៉ោងទេ?
ត្រូវហើយ
អញ្ចឹង រឿងនេះកើតឡើងដោយសារតែបញ្ហាយល់ច្រឡំបន្តិចបន្តួច?
ត្រូវហើយ នេះជាការយល់ច្រឡំទេ
អ្នកទាំងអស់គ្នាគួរសួរខ្លួនឯងមើល៍ ថាតើកុសលប្រាប់ការពិតទៅបងប្អូនទាំងអស់គ្នាហើយរឺនៅ? តើមានការបោះឆ្នោតចង់ដឹងអ្នកណាចង់ធ្វើកូដកម្មឬទេ រឺអ្នកទាំងអស់គ្នាត្រូវគេជំរុញឱ្យធ្វើសកម្មភាពនេះ?
ហើយ អ្នកធ្វើយ៉ាងណាដើម្បីបញ្ឈប់មនុស្សចេញចូលរោងចក្រដោយសិទ្ធិបែបនោះ... ដោយប្រើអំពើហិង្សា និង ការបង្ខំឬ? នេះមិនមែនជាការប្រើសិទ្ធិដ៏ត្រឹមត្រូវដើម្បីធ្វើកូដកម្ម ស្របច្បាប់ទេ... ច្បាប់ការងារ គឺដើម្បីការពារពួកយើង ជួយយើងតែ យើងត្រូវប្រើច្បាប់នោះឱ្យបានត្រឹមត្រូវដែរ?


កុសល មានគំរោងបញ្ឈប់កូដកម្ម បើសិនជាអ្នក
គ្រប់គ្រងយល់ស្រមតាមតំរូវការរបស់គាត់ បើមិន
ដូច្នោះទេគាត់នឹងធ្វើឱ្យមានភាពហ៊ឹកហ្សាទៅ
ពេលអតិថិជនធំមកពិនិត្យ
ថ្ងៃនេះ !
បង វាជាការពិត ឆាប់គួរសំរេច
ថា តើគួរដោះស្រាយយ៉ាងម៉េច
ចំពោះបញ្ហា ដូចករណីខ្ញុំនេះ
....ប៉ុន្តែ ខ្ញុំពិតជាចង់បានលុយ
បន្ថែម ដើម្បីជួយគ្រួសារ
អ្នកទាំងអស់គ្នា...
កុំអាលទៅ... ខ្ញុំមានដំណឹង
ពិសេស សំរាប់អ្នកទាំងអស់
គ្នា
លោកប្រធាន យល់ព្រម
ឱ្យលុយបុណ្យ ហើយគាត់យល់ថាបុគ្គលទទួល
ពតិមានមិនច្បាស់ពីលក្ខខ័ណ្ឌធ្វើការជំនួស


បង ខ្ញុំស្ទើរមិនជឿសោះ សប្បាយចិត្តណាស់ ឥឡូវអាចជួយគ្រួសារ ដូចដែលបានសន្យាហើយ
តែស្តាប់សិន យើងទាំងអស់គ្នាគួរយល់ថានេះជាករណីលើកលែង អ្វីដែលគេធ្វើនេះគឺគេធ្វើដោយស្មោះចំពោះលុយដែលខ្វះនោះ បើគេមិនអោយក៏គេមិនខុសដែរ តែគេនៅតែបើកអោយ
មួយសន្ទុះក្រោយមក...
WB
មើលនែ! អតិថិជនធំៗ!!!
ឥឡូវនេះ ខ្ញុំមានការងារធ្វើច្រើនហើយ នៃក្រោយខ្ញុំនឹងបើកលុយបានច្រើនសំរាប់គ្រួសារខ្ញុំទៀតហើយ!
ប៉ាង!! ប៉ាង!!

ចប់

**សេចក្តីថ្លែងអំណរគុណ**

សៀវភៅនេះត្រូវបានរៀបរៀង និង ផលិតដោយបុគ្គលិករបស់អង្គការ ILO ***គំរោងរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា*** លោក ខននី ប៊ុយ, លោក ជុំ ផល្លី, លោក នៅ តារា និង លោក វុធ លីណូ ។ ម្ចាស់ជំនួយសូមថ្លែងអំណរគុណជាពិសេសចំពោះ លោក ឌីក វូដ (Navigator Communications) អ៊ិន ផល្លីកា, លោក ហៀម សុគន្ធ, លោក ឈិន ស៊ីណារ៉ាក់, កញ្ញា ឌិក សុមរិយ៉ា, លោក ពៅ គីសាន់, វ៉ូដា និង លោក ផង់ សុភី (ដែលជាតួសំដែងកាយវិការត្រូវបានថតយកដូចរូបបេះបិត) សំរាប់ការបរិច្ចាគរបស់ពួកគេដើម្បីផលិតជាសៀវភៅនេះឡើង ។

**វិចិត្រគំនូរដោយ**

លោក ចូសេ អែនស៊ីណា

**Illustrations & Layout by**
**Jose Encinas jose@tonle.net**

**ឧបត្ថម្ភថវិកាដោយ**

សៀវភៅនេះត្រូវបានផលិតឡើងក្រោមការឧបត្ថម្ភថវិកាតាមរយៈកិច្ចខំប្រឹងប្រែងរួមគ្នានៃ មូលនិធិ GAP និង អង្គការ ILO ***គំរោងរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***។ ***គំរោងរោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***ត្រូវបានឧបត្ថម្ភថវិកាដោយ:

អ្នកផ្តល់ជំនួយ

- ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
- ទីភ្នាក់ងារជំនួយ និងអភិវឌ្ឍន៍អន្តរជាតិញូហ្ស៊ីឡែន
- រាជរដ្ឋាភិបាលកម្ពុជា
- ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ

ក្រុមហ៊ុនដែលបានឧបត្ថម្ភជាថវិកាដល់គំរោង និងបានអនុញ្ញាតិអោយប្រើឈ្មោះរបស់ពួកគេ:

- Sears Holdings Corporation
- Gap Inc.
- Levi Strauss & Co.
- H & M Hennes & Mauritz
- Reebok
- Wal-Mart Stores, Inc.
- Phillips - Van Heusen Corporation


សំរាប់ពត៌មានបន្ថែមសូមទំនាក់ទំនង:

***រោងចក្រកាត់ដេរប្រសើរនៅកម្ពុជា***

**អង្គការពលកម្មអន្តរជាតិ**

លេខ៩ ផ្លូវលេខ៣២២ បឹងកេងកង១

ភ្នំពេញ កម្ពុជា

ប្រអប់សំបុត្រលេខ ២៦៤២

ទូរស័ព្ទ : (+៨៥៥) ២៣ ២១២ ៨៤៧
(+៨៥៥) ២៣ ២២០ ៣៦២

ទូរសារ : (+៨៥៥) ២៣ ២១២ ៩០៣

អ៊ីមែល : betterfactories@ilo.org

វ៉ិបសាយ : www.betterfactories.org/ilo

# សារសំខាន់ៗដកស្រង់ពីឈុតនេះ

- កុំបណ្តោយបញ្ហាតូចតាច ឱ្យក្លាយជាបញ្ហាធំបាន
- ទុកឱកាសឱ្យអ្នកគ្រប់គ្រងដោះស្រាយបញ្ហាសិន
- ត្រូវដើរតាមនីតិវិធីដោះស្រាយជំលោះត្រឹមត្រូវដូចខាងក្រោម
  - ការចរចា
  - ការផ្សះផ្សារ
  - អាជ្ញាកណ្តាល